ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ : ០១ ដណ.សណ.ន

# សេចក្តីណែនាំ

## ស្តីពី

## ការរៀបចំ និង ត្រួតពិនិត្យសំណុំឯកសារសុំលិខិតអនុញ្ញាតសាងសង់ សំរាប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង

កន្លងមកក្រសួង បានកត់សំគាល់ឃើញថា មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត/ក្រុង មួយចំនួនបានធ្វើការងារពិនិត្យសំណុំឯកសារសុំលិខិតអនុញ្ញាតសាងសង់បានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសមុននឹងបញ្ជូនមកសាលាខេត្ត/ក្រុងឬ ក្រសួងដើម្បីពិនិត្យនិងសំរេច ក៏ប៉ុន្តែទន្ទឹមនឹងនេះក៏មាន មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង មួយចំនួនទៀត នៅមានចំណុចខ្វះខាតលើការរៀបចំ និងត្រួតពិនិត្យសំណុំឯកសារសុំលិខិតអនុញ្ញាតសាងសង់ ដោយពុំមានរបាយការណ៍បច្ចេកទេស និង យោបល់ជំនាញច្បាស់លាស់ទៅតាមការណែនាំរបស់ក្រសួង ។

ដើម្បីលុបបំបាត់បាតុភាពអសកម្មខាងលើ និងដើម្បីអោយការរៀបចំ និងត្រួតពិនិត្យសំណុំឯកសារសុំលិខិតអនុញ្ញាតសាងសង់កាន់តែមានសុក្រឹត្យភាព ប្រសិទ្ធភាព និង តម្លាភាព ក្រសួងធ្វើការណែនាំដូចខាងក្រោម :

### I. សំណុំឯកសារ និងគំរោងប្លង់ សុំលិខិតអនុញ្ញាតសាងសង់ដែលចាំបាច់

សំណុំឯកសារសុំលិខិតអនុញ្ញាតសាងសង់ ដែលសាម៉ីសំណើត្រូវមានៈ

ក.សំណុំលិខិតសុំអនុញ្ញាតសាងសង់

១- សំណុំលិខិតសុំអនុញ្ញាតសាងសង់ ( ពាក្យសុំ កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន ..............) ដែលត្រូវ មានការចុះហត្ថលេខា ឬ ស្នាមមេដៃរបស់សាម៉ីសំណើ ។

២- ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ថតចំលង ដែលមានធ្វើ និត្យានុកូលកម្មនៅសាលាខេត្ត/ក្រុង ឬ កិច្ចសន្យាជួលដី ឬ ឯកសារបញ្ជាក់ពីការកាន់កាប់ដីសាងសង់ស្របច្បាប់ ។

- ករណីជួលដីរយៈពេលវែង( ១៥ ឆ្នាំ ឡើងទៅ) ត្រូវទៅចុះបន្ទុកនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង ជាមុន ។

៣- អត្តសញ្ញាណសាម៉ីសំណើ : អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំណុំឯកសារសំគាល់និតិបុគ្គល ( ឯកសារ និងលក្ខន្តិកៈក្រុមហ៊ុន, លិខិតឆ្លងដែន, លិខិតប្រគល់សិទ្ធិ.....)

ខ. គំរោងប្លង់ស្នើសុំលិខិតអនុញ្ញាតសាងសង់មាន :

( ចំនួនយ៉ាងតិច ១០ ច្បាប់ )

១- ប្លង់បង្ហាញទីតាំង មាត្រដ្ឋាន ១ ៖ ៥០០០ ឬ ១ ៖ ១០ ០០០

-សញ្ញាបង្ហាញទិស( ទិសខាងជើងទៅលើ)

២- ប្លង់សរុប( ប្លង់ទីតាំងអគារក្នុងដីឡូតិ៍ ) មាត្រដ្ឋាន ១ ៖ ២០០ ឬ ១ ៖ ៥០០ ដែលនៅលើប្លង់នេះបញ្ជាក់ពី :

- ការបោះទីតាំងនៃសំណង់ក្នុងដីឡូតិ៍ដែលជាកម្មវត្ថុនៃពាក្យសុំ
- ឈ្មោះ ឬ លេខផ្លូវធំ តូច និង ទំហំផ្លូវ
- ច្រកចេញចូលក្នុងដីឡូតិ៍
- ជួរតំរង់ផ្លូវ
- ជួរតំរង់នៃអគារ
- ទំហំដីនិងក្រឡាផ្ទៃដីឡូតិ៍ច្បាស់លាស់
- ចំងាយរវាងអគារនីមួយៗ ឬ ច្រើន
- ចំងាយពីព្រំប្រទល់ដីឡូតិ៍ ស្របច្បាប់ ទៅអគារស្នើសុំ
- ចំងាយទៅអគារជិតខាងដែលមានស្រាប់ជាប់ដីឡូតិ៍
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូតិ៍ ( ទីតាំង និង កំពស់)
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូតិ៍ជាប់គ្នា ផ្ទៃបាត និង កំពស់របស់វា
- ការរៀបចំផ្នែកផ្សេងៗនៃដីទំនេរ ( ដីដាំដំណាំ សួនច្បារ កន្លែងចតរថយន្ត )
- របង ( កំពស់ និងទីតាំង )
- បំពង់លូក្រៅអគារ ( រូបធាតុ វិជ្ជមាត្រ ចំណោត គិតកំពស់ រណ្តៅពិនិត្យ )
- កន្លែងតភ្ជាប់ទៅបណ្តាញលូសាធារណៈសំរាប់បញ្ចេញទឹកស្អុយ
- ទីតាំងអាងបង្គន់អនាម័យ អាងចំរោះ និង បណ្តាញប្រព័ន្ធបង្ហូរទឹក
- បណ្តាញទឹកស្អាត
- តារាងនិមិត្តសញ្ញា ឬ អក្សរកាត់ប្រើក្នុងសន្និកប្លង់

៣- តារាងឈ្មោះអគារ ឈ្មោះសន្និកប្លង់ ក្រឡាផ្ទៃសំណង់គ្រប់បន្ទប់ ជាន់ និងក្រឡាផ្ទៃសរុប

៤- ប្លង់អគារគ្រប់ជាន់ មាត្រដ្ឋាន ១ ៖ ១០០ នៅលើប្លង់នេះបញ្ជាក់ពី :

- មុខងារប្រើប្រាស់និងផ្ទៃក្រឡានៃអគារ
- សញ្ញានៃសង្ហារឹមស្របតាមមុខងារប្រើប្រាស់
- សញ្ញាសំគាល់រូបភាពពុះ និង រូបភាពរគារពីគ្រប់ទិស

៥- ប្លង់ដំបូល មាត្រដ្ឋាន ១ ៖ ១០០ នៅលើប្លង់នេះបង្ហាញពី :

- រចនាសម្ព័ន្ធ និង សំភារៈសំរាប់ដំបូល

- មុំ ឬ ភាគរយ ជំរាល របស់ដំបូល
- ទរទឹក និង ទិសដៅលំហូរទឹក

៦- ប្លង់មុខភាពនៃអគារគ្រប់ទិស មាត្រដ្ឋាន ១៖ ១០០ នៅលើប្លង់នេះបង្ហាញពី :

- កំរិតកំពស់កំរាលគ្រប់ជាន់
- កំរិតកំពស់ដីធៀបទៅនឹងកំរាលអគារ
- កំរិតកំពស់ដីធម្មជាតិ
- កំរិតកំពស់ដំបូល និងកំពូលដំបូល
- កំរិតកំពស់ដំបូលទៅវ៉ាស់ និងស្នាបជញ្ជាំងរងស្បូវ
- កំរិតកំពស់អគារ និងទ្រើងផ្កា
- កំណត់សំគាល់សំភារៈបង្ហើយសំរាប់អគារ

៧- ប្លង់ពុះយ៉ាងតិចចំនួនពីរ (បង្ហាញដូចប្លង់មុខភាព) មាត្រដ្ឋាន ១ ៖ ១០០

- ប្លង់ពុះបណ្តោយអគារ ( គ្រប់អគារ ) និង
- ប្លង់ពុះទទឹងអគារ ( គ្រប់អគារ ) មានបង្ហាញពីៈ
  - កំរិតកំពស់កំរាលគ្រប់ជាន់
  - កំរិតកំពស់ដីធៀបទៅនឹងកំរាលអគារ
  - កំរិតកំពស់ដីធម្មជាតិ
  - កំរិតកំពស់ដីចាក់បំពេញ ឬ ដីចូកចេញ
  - កំរិតកំពស់ដំបូល និងកំពូលដំបូល
  - កំរិតកំពស់ដំបូលទៅវ៉ាស់ និងស្នាបជញ្ជាំងរងស្បូវ
  - កំរិតកំពស់អគារ និងទ្រើងផ្កា
  - កំណត់សំគាល់សំភារៈបង្ហើយសំរាប់អគារ
  - ប្លង់បង្គន់អនាម័យ. ប៉ុកជណ្តើរ

៨- ប្លង់បណ្តាញក្រោមដីនានា និង អាងបង្គន់អនាម័យ

- ប្លង់អាងបង្គន់អនាម័យ មាត្រដ្ឋាន ១៖ ៥០ និង អាងចំរោះ មាត្រដ្ឋាន ១៖ ៥០
- ប្លង់បំពង់លូក្រោមដី ( រូបធាតុ វិជ្ជមាត្រ ចំណោត កំរិតកំពស់រណ្តៅពិនិត្យ )
- ប្លង់បង្ហាញកន្លែងតភ្ជាប់បណ្តាញលូសាធារណៈសំរាប់បញ្ចេញទឹកស្អុយចោល

៩- សលាកប័ត្រគណនាផលធៀបផ្ទៃបាតសំណង់ និង សន្ទស្សន៍នៃការប្រើប្រាស់

១០- ភាសាសរសេរលើប្លង់ត្រូវតែជាភាសាខ្មែរ

១១- ប្លង់ត្រូវគូរលើក្រដាស់ A3,A2,A1 ឬ A0 លើកលែងតែក្នុងករណីពិសេសដែលប្លង់មានទំហំធំ អាចប្រើ មាត្រដ្ឋាន ១៖២០០។

១២ ចំពោះសន្លឹកទី១នៃគំរោងប្លង់ចាំបាច់ត្រូវតែមាន ប្លង់បង្ហាញទីតាំង ប្លង់សរុប បទបញ្ជា និង កន្លែងចុះហត្ថលេខា របស់ប្រធានមន្ទីរ និង អភិបាលខេត្ត/ក្រុង ឬ ថ្នាក់ដឹកនាំក្រសួង ។

១៣- គំនូរផ្នាកសន្លឹកប្លង់ (កាទូស) នៃសន្លឹកប្លង់និមួយៗត្រូវអនុវត្តតាមគំរូដែលមានភ្ជាប់មកជាមួយ

១៤- គំរោងប្លង់ស្ថាបត្យកម្មត្រូវមានជាលក្ខណៈជាតិ

១៥- គំរោងប្លង់ស្ថាបត្យកម្មដែលមានក្រឡាផ្ទៃធំជាង ៥០០ ម៉ែត្រការ៉េ ត្រូវមានស្ថាបត្យករជាអ្នកសិក្សាគំរោងដោយមាន សញ្ញាប័ត្រថតចំលងដែលមានធ្វើនិត្យានុកូលកម្មនៅសាលាខេត្ត/ក្រុង ភ្ជាប់មកជាមួយ ។ អ្នកសិក្សាគំរោងប្លង់ត្រូវចុះហត្ថលេខាទទួលខុសត្រូវនៅគ្រប់សន្លឹកប្លង់ដែលស្នើសុំសាងសង់

## II. សំណុំឯកសារដែលមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង ត្រូវបំពេញ

១-សលាកប័ត្រដីឡូតិ៍ ត្រូវបញ្ជាក់ពី :

- ទីតាំងដីឡូតិ៍ដែលជាកម្មវត្ថុនៃពាក្យសុំ
- ទីតាំងដីឡូតិ៍ជាប់គ្នា
- ផ្លូវចូលទៅដីឡូតិ៍, លក្ខណៈរបស់ផ្លូវ និង ទំហំផ្លូវ
- ឈ្មោះ ឬ លេខផ្លូវធំ និង ផ្លូវតូច
- ទំហំ និង ផ្ទៃក្រឡាដីឡូតិ៍ (ត្រូវបញ្ជាក់ពីទំហំដីវាស់ជាក់ស្តែង និង ទំហំដីក្នុងប័ណ្ណ )
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូតិ៍សុំសាងសង់ ( ទីតាំង និង កំពស់ )
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូតិ៍ជាប់គ្នា ផ្ទៃបាត និង កំពស់របស់វា
- មាត្រដ្ឋានប្លង់ រង្វាស់ជ្រុង និងមុំនីមួយៗ ការកំណត់ទិស
- ចំណុចនីងថ្កល់សំរាប់ជាគោលសំគាល់កំពស់ដែលបោះនៅលើដីឡូតិ៍
- បន្ទាត់ជួរតំរង់ផ្លូវសាធារណៈ
- ប្លង់សលាកប័ត្រនេះត្រូវធ្វើឡើងនិងចុះហត្ថលេខាដោយមន្ត្រីសុរិយោដី ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក/ខ័ណ្ឌ និង ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង

២- របាយការណ៍ត្រួតពិនិត្យទីតាំងរបស់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក/ខ័ណ្ឌ

៣- ការពិនិត្យគំរោងប្លង់ស្នើសុំលិខិតអនុញ្ញាតសាងសង់ត្រូវ :

- គោរពតាមគោលការណ៍ច្បាប់ អនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ និង បទដ្ឋានគតិយុត្តិជាធរមាន ។
- ពិនិត្យគ្រប់សំណុំឯកសារ និងគ្រប់សន្លឹកប្លង់សុំលិខិតអនុញ្ញាតសាងសង់
- គ្រប់សន្លឹកប្លង់ត្រូវមានចុះហត្ថលេខាដោយប្រធានការិយាល័យរៀបចំដែនដី និង នគរូបនីយកម្ម និង ប្រធានការិយាល័យសំណង់ នៃ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង ។

៤- របាយការណ៍បច្ចេកទេសរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង

ក្នុងរបាយការណ៍បច្ចេកទេសត្រូវបញ្ជាក់ឱ្យច្បាស់ពី :

ក- ប្រវត្តិរបស់ដី ព្រំប្រទលភាពដី និងលក្ខណៈនៃការកាន់កាប់ដី

ខ- សំណង់ ក្នុងនោះមានប្រភេទ មុខងារ ទំហំ និងកំពស់អគារនីមួយៗព្រមទាំងក្រឡាផ្ទៃតាមជាន់ នីមួយៗ ក្រឡាផ្ទៃអគារនីមួយៗ និងក្រឡាផ្ទៃសរុបនៃគំរោងប្លង់ទាំងមូល

គ- លក្ខណៈនគរូបនីយបញ្ញត្ត ដែលក្នុងនោះមានៈ

- គម្លាតរបស់អគារពីគ្រប់ទិសទៅព្រំដីកាន់កាប់ស្របច្បាប់
- កំពស់អគារ
- ផលធៀបផ្ទៃបាតសំណង់ទៅនឹងផ្ទៃដីឡូត៍កាន់កាប់ស្របច្បាប់
- សន្ទស្សន៍ប្រើប្រាស់របស់សំណង់

ឃ- យោបល់ និង ការវាយតំលៃ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង

## III. សមត្ថកិច្ចជំនាញពាក់ព័ន្ធ

-ក្នុងករណីដែលគំរោងស្នើសុំមានពាក់ព័ន្ធនឹងជំនាញនានា ( បរិស្ថាន ឧស្សាហកម្ម អាជ្ញាធរអប្សរា............)សំណុំឯកសារសុំលិខិតអនុញ្ញាតសាងសង់ត្រូវភ្ជាប់មកជាមួយមតិយោបល់របស់អង្គភាពពាក់ព័ន្ធទាំងនោះ ។

## IV. បើក និង បិទ ការដ្ឋាន

- បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតសាងសង់ ម្ចាស់សំណង់ត្រូវសុំលិខិតអនុញ្ញាតបើកការដ្ឋានពី
  - មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង ប្រសិនបើសំណង់ជាសមត្ថកិច្ចរបស់សាលាខេត្ត/ក្រុង
  - អគ្គនាយកដ្ឋានសំណង់ ប្រសិនបើសំណង់ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បន្ទាប់ពីបានបញ្ចប់ការសាងសង់ ម្ចាស់សំណង់ត្រូវសុំលិខិតអនុញ្ញាតបិទការដ្ឋានពី
  - មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង ប្រសិនបើសំណង់ជាសមត្ថកិច្ចរបស់សាលាខេត្ត/ក្រុង
  - អគ្គនាយកដ្ឋានសំណង់ ប្រសិនបើសំណង់ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

ទទួលបានសេចក្តីណែនាំនេះ គ្រប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង ត្រូវអនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់ ។

ភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០០៦

**ទេសរដ្ឋមន្ត្រី**

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- គ្រប់សាលាខេត្ត-ក្រុង
- គ្រប់អគ្គនាយកដ្ឋានរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ឯកសារ កាលប្បវត្តិ